# អ្វីដែលត្រូវពិចារណាមុននឹងទទួលយកកម្ចី ឬការវិនិយោគពីមិត្តភក្តិ និងគ្រួសារ

## Things to Consider Before Getting a Loan or Investment from Friends and Family

ការខ្ចីលុយពីមិត្តភក្តិ និងគ្រួសារគឺច្រើនតែជាដំណោះស្រាយដែលងាយស្រួលជាងគេ និងថោកថ្លៃជាងគេ ក្នុងការទទួលបានដំណោះស្រាយហិរញ្ញវត្ថុសម្រាប់អាជីវកម្មរបស់អ្នក។ នេះព្រោះតែមិត្ត និងគ្រួសារ របស់អ្នកជាធម្មតាមិនត្រូវការឯកសារអ្វីពីអ្នក ដូចអ្វីដែលអ្នកត្រូវរៀបចំសម្រាប់ធនាគារ ឬស្ថាប័នមីក្រូ ហិរញ្ញវត្ថុឡើយ ហើយអ្នកក៏មិនតម្រូវឱ្យមានទ្រព្យតម្កល់ដែរ។ ទោះបីយ៉ាងណា បើសិនជាអ្នកធ្វើមិន បានត្រឹមត្រូវទេ វាអាចបង្កឱ្យមានបញ្ហាទំនាក់ទំនងដោយសារតែជួបរឿងស្មានមិនដល់មួយចំនួន។ បើសិនអ្នកគ្រោងខ្ចីលុយពីមិត្តភក្តិ និងគ្រួសារ ខាងក្រោមនេះមានចំនុចសំខាន់ៗមួយចំនួនដែលអ្នក ត្រូវពិចារណា៖

Borrowing money from friends and family is often the easiest and cheapest way to get financing for your business. This is because your friends and family will not usually require all the documents you would need for a bank or MFI loan, and usually they won't require collateral. However, if not done right it can cause problems with the relationship because of unmet expectations. If you are going to borrow money from friends and family then below are some key points to consider:

### ១. តើអ្នកមានផែនការអាជីវកម្ម និងការព្យាករណ៍លំហូរសាច់ប្រាក់ហើយឬនៅ?
1. Do you have a business plan and cashflow forecast?

ទោះជាមិត្តភក្តិ ឬគ្រួសារអ្នកមិនត្រូវការក៏ដោយ ក៏ការបង្ហាញទៅពួកគេនូវឯកសារទាំងនេះមិនត្រឹមតែជួយបង្កើនទំនុកចិត្តរបស់ពួកគេប៉ុណ្ណោះទេ វាថែមទាំងជាការអនុវត្តល្អ និងជួយបង្កើននូវឱកាស ជោគជ័យក្នុងការធ្វើអាជីកម្មផងដែរ។

Even though your friends or family may not require this, by showing them you have this not only will it increase their confidence it is good business practice and will increase the chance of business success.

### ២. ត្រូវមានការរំពឹងទុកច្បាស់លាស់
2. Be Clear about expectations

| | |
|---|---|
| កម្ចី<br>Loan | បើសិនជាពួកគេឱ្យអ្នកខ្ចីលុយ ភាគីទាំងសងខាងត្រូវតែកំណត់រយៈពេលនៃកម្ចីឱ្យបានច្បាស់លាស់ អត្រាការប្រាក់ (បើសិនមាន) និងលក្ខខណ្ឌជាក់លាក់ថាតើមានដំណោះស្រាយអ្វីចំពោះករណីអ្នកខកខានក្នុងការបង់សង។<br><br>If they are loaning you money, be sure both parties know the terms, interest rates (if any), and be clear about what happens if you miss a payment. |
| | ពិភាក្សាគ្នា៖ តើមានអ្វីកើតឡើង បើសិនអ្នកមិនអាចសងត្រឡប់កម្ចីបានដោយសារតែអាជីវកម្មអ្នកបរាជ័យ?<br>ត្រូវប្រាកដថាគ្រប់គ្នាយល់ច្បាស់ពីហានិភ័យនេះ។<br><br>Discuss together: What happens if you cannot pay back the loan because your business fails?<br>Make sure that everyone understands this risk. |

| | | |
|---|---|
| ការវិនិយោគ (ទុន) Investment (Equity) | បើសិនពួកគេវិនិយោគក្នុងអាជីវកម្មរបស់អ្នក វាសំខាន់ណាស់ដែលពួកគេត្រូវដឹងថាតើពួកគេនឹងបានទទួលភាគលាភចំនួនប៉ុន្មានពីអាជីវកម្មអ្នក? (ឧ. ២០%, ៤០% ជាដើម)<br><br>If they are investing in your business then it is important to know how much of the business they will get in return (e.g. 20%, 40%, etc.) |
| | តើគេនឹងទទួលបានលុយរបស់គេទៅវិញដោយរបៀបណា? ជាប្រាក់ចំណេញ? ជាប្រាក់ចំណូលពីការលក់របស់អាជីវកម្ម? ប្រសិនបើវាជាប្រាក់ចំណេញ តើពួកគេមានការរំពឹងទុកប៉ុនណា?<br><br>How will they get their money back? Profits? Sale of the business? If its profits, what are their expectations? |
| | តើពួកគេយល់ច្បាស់ពីហានិភ័យឬទេ? តើមានអ្វីកើតឡើង បើសិនអាជីវកម្មដួលរលំ?<br><br>Are they clear about the risk? What happens if the business fails? |
| | តើពួកគេនឹងធ្វើជាដៃគូអាជីវកម្ម ដែលចូលរួមគ្រប់គ្រងអាជីវកម្មជាមួយគ្នា ឬក៏ មិនចូលរួមគ្រប់គ្រងអាជីវកម្មទេ?<br><br>Will they be involved in the business or a silent partner? |
| | តើពួកគេត្រូវការរបាយការណ៍ដូចម្ដេច?<br><br>What reporting will they require? |

៣. សរសេរជាលាយលក្ខណ៍អក្សរ

**3. Put it in writing**

| | |
|---|---|
| ហេតុអ្វី? Why? | ទោះបីជាចំណុចនេះហាក់ដូចជាមិនចាំបាច់ តែការរៀបចំនូវឯកសារជាលាយ លក្ខណ៍អក្សរ អាចជួយការពារអ្នក និងមិត្ត ឬគ្រួសាររបស់អ្នកបាន។ អ្នកអាចនឹងត្រូវត្រឡប់ទៅយោងលើឯកសារកិច្ចព្រមព្រៀងនោះបានជានិច្ច នៅពេលណាដែលមានការមិនចុះសម្រុងគ្នាណាមួយកើតឡើង។<br><br>Although this may not seem necessary, having it in writing protects you and your friends or family. You can always refer back to the agreement if there are any disagreements. |
| ធ្វើរបៀបណា? How? | សរសេរនូវកិច្ចព្រមព្រៀងម្ចាស់ភាគហ៊ុន (មានទម្រង់គំរូនៅទីនេះ)<br><br>Write a Shareholders Agreement (an example template is here) |
| | ត្រូវច្បាស់ថាអ្នកមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ហើយភាគីទាំងពីរ បានចុះហត្ថលេខាដោយផ្ទាល់។ ល្អបំផុតដែលអ្នកត្រូវមានអ្នកទី៣ ឬទី៤ (គួរតែជាបុគ្គលអព្យាក្រឹត ឬក៏អាចជាមេធាវី បើសិនអ្នកមានលទ្ធភាពបង់ថ្លៃមេធាវី)<br><br>Make sure you have the agreement written down, and all parties sign the original copy. It is best to have a 3rd or 4th person (ideally a neutral person or even a lawyer, if you can afford this). |

| | |
|---|---|
| | ត្រូវច្បាស់ថាម្នាក់ៗត្រូវមានឯកសារកិច្ចព្រមព្រៀងច្បាប់ដើម១ច្បាប់។<br><br>Make sure everyone has their own copy of the agreement. |
| | រក្សាឯកសារដែលបានចុះហត្ថលេខារួច ជាច្បាប់ឌីជីថល(ស្កែន)មួយទុកក្នុងករណីអ្នកបាត់ឯកសារដើម។<br><br>Keep a digital (scanned) copy of the signed agreement in case you lose the original hard copy. |